# ទូតជាតក



ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**លោលភិក្ខុ** (ភិក្ខុល្មោភ) មួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **យស្សត្ថា ទូរមាយន្តិ** ដូច្នេះជាដើម ។

រឿងរ៉ាវ (បច្ចុប្បន្ន) នឹងមានជាក់ច្បាស់ ក្នុង**ចក្កវាកជាតក** នវកនិបាត ។ ព្រះសាស្តាត្រាស់ហៅភិក្ខុរូបនោះមកហើយ ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះក៏ទេ សូម្បីក្នុងកាលមុន អ្នកក៏ជាអ្នកល្មោភដែរ ព្រោះសេចក្តីល្មោភ អ្នកបិះតែនឹងត្រូវកាត់ក្បាលដោយដាវ ហើយទ្រង់នាំអតីតនិទានមកថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងព្រះនគរពារាណសី ព្រះពោធិសត្វជាឱរស របស់ព្រះបាទព្រហ្មទត្តនោះ ល្មមចម្រើនវ័យហើយក៏បានសិក្សារៀនសូត្រសិល្បសាស្រ្តទាំងពួង ក្នុងក្រុងតក្កសិលា ពេលព្រះបិតាកន្លងទៅ ក៏បានតាំងនៅក្នុងរាជសម្បត្តិ សោយភោជនដ៏បរិសុទ្ធ ព្រោះហេតុនោះ ព្រះអង្គទើបមានព្រះនាមថា ព្រះបាទ**ភោជនសុទ្ធិករាជ** ។ បានមកឮថា ព្រះអង្គទ្រង់សោយភត្ត ដោយការតាក់តែង

បែបនោះ គ្រាន់តែភាជនៈភត្តមួយចំណាយអស់តម្លៃដល់ទៅមួយសែន ។ កាលទ្រង់សោយក៏មិនសោយខាងក្នុងព្រះរាជមណ្ឌប ព្រះអង្គប្រាថ្នាឲ្យមហាជន ដែលបានឃើញការរៀបចំតាក់តែងភោជនរបស់ព្រះអង្គ ឲ្យមានសេចក្ដីប្រាថ្នាធ្វើបុណ្យ ទើបឲ្យសាងរតនមណ្ឌបត្រង់ទ្វារព្រះរាជវាំង វេលានឹងសោយ ក៏ឲ្យប្រដាប់តាក់តែងរតនមណ្ឌបនោះ ហើយទ្រង់ប្រថាប់លើរាជបល្ល័ង្ក ខាងក្រោមស្វេតច្ឆត្រ ហែហមដោយខត្តិយកញ្ញាទាំងឡាយ ហើយសោយព្រះក្រយាហារដែលមានរសគ្រប់យ៉ាង ដោយភាជនៈមាសដែលមានតម្លៃមួយសែនកហាបណៈ ។

គ្រានោះ មានលោលបុរសម្នាក់ បានឃើញវិធីសោយព្រះក្រយាហាររបស់ព្រះរាជានោះ ចង់នឹងបរិភោគភោជននោះ កាលមិនអាចនឹងអត់ទ្រាំសេចក្ដីប្រាថ្នាបាន ទើបគិតថា ឧបាយនេះល្អ ទើបស្លៀកសំពត់ឲ្យមាំហើយលើកដៃឡើងម្នាងស្រែកសម្លេងខ្លាំងៗថា លោកដ៏ចម្រើនទាំងឡាយ យើងជាទូត យើងជាទូត រួចដើរចូលទៅគាល់ព្រះរាជា ។ ដោយសម័យនោះ ក្នុងជនបទនោះ អ្នកណាៗ រមែងមិនហាមអ្នកដែលពោលថា យើងជាទូតឡើយ ព្រោះដូច្នោះ មហាជនទើបញែកចេញជាពីរផ្នែកឲ្យឱកាស ។ បុរសនោះ ស្ទុះទៅស្រវាចាប់យកដុំភត្តមួយអំពីភាជនៈមាស របស់ព្រះរាជាមកដាក់មាត់ ។ លំដាប់នោះ រាជបុរសគិតថា យើងនឹងកាត់ក្បាលរបស់បុរសនេះ ទើបហូតដាវចេញមក ។ ព្រះរាជាត្រាស់ហាមថា កុំប្រហារ ហើយត្រាស់ថា អ្នកកុំខ្លាច ចូរបរិភោគចុះ ហើយទ្រង់លាងព្រះហស្ត រួចប្រថាប់ ។ ក្នុងវេលាដែលបុរសនោះសម្រេចការបរិភោគ ព្រះរាជាឲ្យប្រទានទឹកផឹក និងស្លាម្លូ ដល់បុរសនោះ ហើយត្រាស់សួរថា នែបុរសដ៏ចម្រើន អ្នកពោលថា ជាទូត អ្នកឯងជាទូតរបស់ព្រះរាជាណា ។ បុរសនោះក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់តណ្ហា ជាទូតរបស់ផ្ទៃ តណ្ហាធ្វើទូលព្រះបង្គំឲ្យជាទូត រួចបញ្ជាទូលព្រះបង្គំហើយបញ្ជូនមកថា អ្នកចូរទៅ ដូច្នេះបុរសនោះក៏ពោល ២ គាថាជាដំបូងថា

យស្សត្ថា ទូរមាយន្តិ, អមិត្តមបិ យាចិតុំ;
តស្សូទរស្សហំ ទូតោ, មា មេ កុជ្ឈ រថេសភ។

*សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយ ដើម្បីសូមនូវវត្ថុនឹងបុគ្គលសូម្បីជាសត្រូវ ដើម្បីប្រយោជន៍ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុង ពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។*

យស្ស ទិវា ច រត្តោ ច, វសមាយន្តិ មាណវា;
តស្សូទរស្សហំ ទូតោ, មា មេ កុជ្ឈ រថេសភា។

*មាណពទាំងឡាយ លុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់ ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។*

*ព្រះរាជាបានស្តាប់ពាក្យរបស់បុរសនោះហើយ ទ្រង់ព្រះតម្រិះថា សេចក្តីនោះពិត សត្វទាំងនេះជាទូតរបស់ផ្ទៃ ត្រាច់ទៅដោយអំណាចតណ្ហា និងតណ្ហារមែងចាត់ចែងសត្វទាំងនេះ បុរសនោះពោលពាក្យជាទីពេញចិត្តយើងក្រៃលែងណាស់ ទ្រង់ត្រេកអរនឹងបុរសនោះ ហើយត្រាស់ព្រះគាថាទី ៣ ថា ៖*

ទទាមិ តេ ព្រាហ្មណា រោហិណីនំ, គវំ សហស្សំ សហ បុង្គវេន;
ទូតោ ហិ ទូតស្ស កថំ ន ទជ្ជំ, មយម្បិ តស្សេវ ភវាម ទូត។

*ម្នាលព្រាហ្មណ៍ យើងឲ្យនូវគោសម្បុរក្រហម ១ ពាន់ ព្រមទាំងគោបា ដល់អ្នក ព្រោះយើងជាទូត (របស់ផ្ទៃ) នឹងមិនឲ្យដល់អ្នកជាទូត (របស់ផ្ទៃដែរ) ដូចម្តេចកើត យើងទាំងឡាយ សុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា ។*

*គ្រាត្រាស់យ៉ាងនេះហើយ ទ្រង់មានព្រះទ័យត្រេកអរថា បុរសប្រាប់ហេតុ ដែលយើងមិនធ្លាប់បានស្តាប់ ដូច្នេះទើបប្រទានយសធំដល់បុរសនោះ ។*

ព្រះសាស្តានាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ និងប្រជុំជាតក ក្នុងវេលាចប់សច្ចៈ លោលភិក្ខុបានតាំងនៅក្នុងសកទាគាមិផល ជនជាច្រើនបានជាព្រះសោតាបន្នជាដើម ។

**តទា លោលបុរិសោ ឯតរហិ លោលភិក្ខុ អហោសិ** លោលបុរសក្នុងកាលនោះ បានមកជាលោលភិក្ខុក្នុងឥឡូវនេះ

**ភោជនសុទ្ធិកោរាជា បន អហមេវ អហោសិំ** ចំណែកព្រះបាទភោជន- សុទ្ធិករាជ គឺ **តថាគត** នេះឯង ។

ចប់ ទូតជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត សង្កប្បវគ្គ បិដកលេខ ៥៨ ទំព័រទី ១៤៦)

ថ្ងៃ ច័ន្ទ ២ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ១៣ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ